00824482

E202/1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 11 / 06 / 2012
ម៉ោង (Time/Heure): 10:40
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

សំណុំរឿងលេខ: ០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ

**Case File/Dossier No. 002/19-09-2007/ECCC/TC**

ចំណាត់ថ្នាក់ឯកសារ៖ **សាធារណៈ**

# ដីកាកោះអ្នកជំនាញ

យើង **នុច ផារី** និង Natacha WEXELS-RISER ជាក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូង នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) កោះហៅ៖

| | |
|---|---|
| ឈ្មោះ | សាស្ត្រាចារ្យ David CHANDLER |
| ភេទ | ប្រុស |
| អាយុ | ៧៩ ឆ្នាំ |
| មុខរបរ | ប្រវត្តិវិទូ និងជាសាស្ត្រាចារ្យ |
| សញ្ជាតិ | អាមេរិកកាំង |
| ទីលំនៅបច្ចុប្បន្ន | ទីក្រុង Melbourne ប្រទេស Australia |

ឱ្យចូលមកកាន់សាលសវនាការធំនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលមានទីតាំងស្ថិតនៅផ្លូវជាតិលេខ ៤ សង្កាត់ ចោមចៅ ខណ្ឌ ពោធិ៍សែនជ័យ រាជធានីភ្នំពេញ នៅវេលាម៉ោង ៨.៣០ ព្រឹក នៅថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០១២ ដើម្បីឆ្លើយឱ្យពត៌មានរហូតដល់ចប់ការផ្តល់ចំលើយពាក់ព័ន្ធនិងសំណុំរឿងលេខ ០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ ដែលមានជនជាប់ចោទឈ្មោះ៖ នួន ជា កើតនៅថ្ងៃទី ០៧ ខែ

កក្កដា ឆ្នាំ ១៩២៦ អៀង សារី កើតនៅថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩២៥ និង ខៀវ សំផន កើតនៅថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ១៩៣១ ដែលបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវចុះថ្ងៃទី១២ ខែ សីហា ឆ្នាំ ១៩៤៩ ។

**បញ្ជាក់៖** បុគ្គលពាក់ព័ន្ធត្រូវបានកោះហៅក្នុងឋានៈជាអ្នកជំនាញ។ ចំពោះពេលវេលាដែលបានកំណត់ខាងលើគឺគ្រាន់តែជាការចង្អុលបង្ហាញប៉ុណ្ណោះ ហើយពេលវេលានេះគឺអាស្រ័យលើកាលវិភាគនៃដំណើរការសវនាការ ។

បុគ្គលដែលបានកោះហៅត្រូវយកមកជាមួយនូវឯកសារសម្គាល់អត្តសញ្ញាណ និងរាល់ឯកសារដែលពាក់ព័ន្ធនឹងសំណុំរឿងខាងលើ ។

**<u>សូមជូនភ្ជាប់មកជាមួយនូវ៖</u>**

- ដីកាកំណត់កាលបរិច្ឆេទនៃការធ្វើសេចក្តីសន្និដ្ឋានចោទប្រកាន់ និងសវនាការលើអង្គសេចក្តីនៃសំណុំ-រឿង ០០២ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១១ ដែលបានចេញដោយអង្គជំនុំជម្រះ (ឯកសារ E131) ។
- អនុស្សរណៈដែលបានចេញដោយចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង ដែលមានចំណងជើងថា "សាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញក្រុមបន្ទាប់ ដែលអង្គជំនុំជម្រះនឹងស្តាប់សក្ខីកម្មក្នុងសំណុំរឿង ០០២/០១" ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១២ (ឯកសារ E172) (អ្នកជំនាញដែលមានរហស្សនាម *TCE-11*) ។
- អនុស្សរណៈដែលបានចេញដោយចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង ដែលមានចំណងជើងថា "ព័ត៌មានបច្ចុប្បន្នភាពទាក់ទងនឹងការកំណត់កាលបរិច្ឆេទស្តាប់សក្ខីកម្មរបស់អ្នក-ជំនាញ ដែលភាគីបានស្នើសុំ" ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១២ (ឯកសារ E172/24) ។

ភ្នំពេញ ថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១២

ក្រឡាបញ្ជី

**ឌុច ផារី** **Natacha WEXELS-RISER**

# ការទទួលស្គាល់អំពីការជូនដំណឹងដីកាកោះ

យើង ជាមន្ត្រីតុលាការនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានប្រគល់ដីកាកោះនេះឲ្យឈ្មោះ ទីលំនៅបច្ចុប្បន្ននៅ ..........................................................

..........................................................................................

ទីកន្លែងប្រគល់ និងទទួលដីកា៖..........................................................

កាលបរិច្ឆេទប្រគល់ និងទទួលដីកា ៖..........................................................

រួចហើយ ដោយយើងបានទុកចុងដីកាកោះនេះមួយច្បាប់ឲ្យសាម៉ីខ្លួន ហើយបានប្រាប់សាម៉ីខ្លួនត្រូវប្រគល់ចុងដីកាកោះនេះដល់ក្រឡាបញ្ជី នៅពេលដែលខ្លួនចូលទៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

**អ្នកទទួល** **អ្នកប្រគល់**